# កិច្ចប្រជុំលេខាធិការដ្ឋាន គ.ជ.អ.ប

## សាលប្រជុំលេខាធិការដ្ឋាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥

**របាយការណ៍សង្ខេប**
**ស្តីពី**
**កិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**



# វឌ្ឍនភាពនៃកិច្ចដំណើរការផ្ទេរមុខងារ

| កំពុងរៀបចំ បញ្ជីមុខងារ | បានបញ្ជប់ បញ្ជីមុខងារ | បានបញ្ជប់ ពិនិត្យមុខងារ |
|---|---|---|
| 1. ក្រសួងទេសចរណ៍ | 1. ក្រសួងអភិវឌ្ឍន៍ជនបទ | 1. ក្រសួងអភិវឌ្ឍន៍ជនបទ |
| 2. ក្រសួងវប្បធម៌ | 2. ក្រសួងកសិកម្ម | 2. ក្រសួងអប់រំ |
| 3. ក្រសួងពាណិជ្ជកម្ម | 3. ក្រសួងសុខាភិបាល | 3. ក្រសួងសង្គមកិច្ច |
| 4. ក្រសួងឧស្សាហកម្ម | 4. ក្រសួងអប់រំ | 4. ក្រសួងបរិស្ថាន |
| 5. ក្រសួងរ៉ែ និងថាមពល | 5. ក្រសួងសង្គមកិច្ច | 5. ក្រសួងសុខាភិបាល |
| 6. ក្រសួងសាធារណការ | 6. ក្រសួងបរិស្ថាន | |
| 7. ក្រសួងរៀបចំដែនដី | | |
| 8. ក្រសួងធនធានទឹក | | |

# ក្រសួងអប់រំ

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ១១
  - មុខងាររង៖ ៨០
  - អនុមុខងាររង/សកម្មភាព៖ ៥៧៣
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងារចំនួន ២ រួមមាន
  - ការអប់រំកុមារតូច (ស្នើផ្ទេរមុខងាររងចំនួន៦/៣៤)
  - ការអប់រំក្រៅប្រព័ន្ធ (ស្នើផ្ទេរមុខងាររងចំនួន១/៤២)
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និងគ.ជ.អ.ប អំពីការផ្ទេរមុខងារ: ១. **ការគ្រប់គ្រងបឋមសិក្សា** ២. **ការអប់រំកុមារតូច** និង៣. **ការអប់រំក្រៅប្រព័ន្ធ** ទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក
  - កិច្ចប្រជុំក្រុមការងារបច្ចេកទេសនៅក្រសួងអប់រំនាថ្ងៃស្អែក



# ក្រសួងសុខាភិបាល

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៥
  - មុខងាររង៖ ៣១
  - អនុមុខងាររង/សកម្មភាព៖ ៨០
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - អនុវត្តសាកល្បងការធ្វើប្រតិភូកម្មនូវមុខងារផ្តល់សេវាសុខភាពនៅមណ្ឌលសុខភាពក្នុងស្រុកចំនួន៥នៅក្នុងខេត្តចំនួន២ គឺខេត្តបាត់ដំបង និងខេត្តពោធិសាត់
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និងគ.ជ.អ.ប លើការផ្ទេរមុខងារ**គ្រប់គ្រងស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពដែលមានវិសាលភាពគ្របដណ្តប់ក្នុងដែនសមត្ថកិច្ចនៃស្រុក១** ទៅឱ្យរដ្ឋបាលថ្នាក់ស្រុកទាំងនោះ
  - **ព័ត៌មានពីក្រសួងសុខាភិបាល៖** ស្នើឱ្យពិនិត្យលើការផ្ទេរការិយាល័យស្រុកប្រតិបត្តិដែលគ្រប ដណ្តប់មួយខេត្ត ទៅឱ្យរដ្ឋបាលខេត្តនោះ (ខេត្តប៉ៃលិន ខេត្តកែប ...)

# ក្រសួងអភិវឌ្ឍន៍ជនបទ

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៩
  - មុខងាររង៖ ៣៨
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងាររងចំនួន៥ រួមមាន
  - ការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ
  - អនាម័យជនបទ (សាកល្បងក្នុងស្រុកចំនួន១០)
  - ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ(សាកល្បងក្នុងស្រុកចំនួន០៧)
  - ដាក់ផ្លាកសញ្ញាចរាចរណ៍លើផ្លូវជនបទ
  - ជួសជុលផ្លូវជនបទមានលក្ខណៈជាប្រចាំ
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - អនុវត្តសាកល្បងផ្ទេរមុខងារអនាម័យជនបទ (ស្រុកចំនួន១០) និងមុខងារជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (ស្រុកចំនួន០៧)
  - ក្រុមការងារបច្ចេកទេសបាន និងកំពុងសិក្សាដើម្បីលើកសំណើជូនថ្នាក់ដឹកនាំក្រសួង និង គ.ជ.អ.ប ក្នុងការផ្ទេរមុខងារ**សាងសង់ និងជួសជុលផ្លូវជនបទ (ប្រភេទទី២ ទី៣ និងទី៤)** ទៅឱ្យរដ្ឋបាល<u>ក្រុង ស្រុក</u>
  - **ព័ត៌មានពីក្រសួងអភិវឌ្ឍន៍ជនបទ៖**ស្នើឱ្យពិចារណាផ្ទេរមុខងារដូចបានកំណត់ក្នុង របាយការណ៍

# ក្រសួងបរិស្ថាន

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៨
  - មុខងាររង៖ ៤០
- **ចំនួនមុខងារដែលស្នើផ្ទេរ៖** មុខងាររងចំនួន៥ រួមមាន
  - ការពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជន និងតាមទីសាធារណៈ
  - ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាននៃគម្រោងវិនិយោគ
  - ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
  - ការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុ
  - ការពង្រឹងការងារអប់រំបរិស្ថាន (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ)
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - បានរៀបចំបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងនៅតាមទីប្រជុំជន (ក្រុមការងារកំពុងរៀបចំសេចក្តីថ្លែងហេតុសម្រាប់ដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច)
  - បាន និងកំពុងរៀបចំសេចក្តីព្រាងប្រកាសសម្រាប់ការផ្ទេរមុខងារចំនួន៤ផ្សេងទៀត រួមមាន ១. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ២. ការគ្រប់គ្រងសហគមន៍ ៣. ការបញ្ជ្រាបភាពធននឹងអាកាសធាតុ និង៤. ការពង្រឹងការងារអប់រំបរិស្ថាន

# ក្រសួងសង្គមកិច្ច

- **ចំនួនមុខងារដែលបានកំណត់ក្នុងរបាយការណ៍៖**
  - មុខងារ៖ ៨
  - មុខងាររង៖ ៣៧
  - អនុមុខងាររង (សកម្មភាព)៖ ១៤២
- **ចំនួនមុខងារដែលស្នើផ្ទេរឆ្នាំ២០១៥៖** មុខងាររងចំនួន ៥ រួមមាន
  - ផ្តល់សេវាថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងមណ្ឌល
  - ផ្តល់សេវាថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងគ្រួសារ និងសហគមន៍
  - ចុះកិច្ចព្រមព្រៀងជាមួយអង្គការជាតិ និងអន្តរជាតិ
  - ផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនរងគ្រោះ និងជនងាយរងគ្រោះ
  - ស្រង់ទិន្នន័យជនរងគ្រោះ និងជនងាយរងគ្រោះ
- **ការរៀបចំសម្រាប់ការផ្ទេរ៖**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងប្រកាស និងសេចក្តីណែនាំសម្រាប់ការផ្ទេរមុខងារ ៖ ១. ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យខេត្តបាត់ដំបង ២. ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យក្រុង ស្រុកចំនួន១០ ក្នុងខេត្តបាត់ដំបង និង៣. ការផ្តល់សេវាថែទាំកុមាររងគ្រោះនៅក្នុងសហគមន៍ទៅឱ្យឃុំ សង្កាត់ក្នុងក្រុង ស្រុកទាំង១០ខាងលើ

7

# បញ្ហាប្រឈមសំខាន់ៗ

- ភាពយឺតយ៉ាវនៃការរៀបចំសេចក្តីសម្រេចរួម
- នីតិវិធីនៃកិច្ចដំណើរការរៀបចំត្រូវចំណាយពេលច្រើន
- ក្រុមការងាររបស់ក្រសួង ស្ថាប័នមានភាពមមាញឹកនឹងការងារស្នូលរបស់ខ្លួន
- យន្តការផ្ទេរធនធានហិរញ្ញវត្ថុ
- យន្តការផ្ទេរធនធានមនុស្ស

# អរគុណ

# កិច្ចប្រជុំកម្រិតបច្ចេកទេស
# ដើម្បីពិភាក្សាលើកិច្ចដំណើរការផ្ទេរមុខងារ
# ក្នុងវិស័យអប់រំ

## មុខងារស្នូលនៃក្រសួងអប់រំ

| ល.រ | មុខងារស្នូល | # មុខងាររង |
|---|---|---|
| 1 | ហេដ្ឋារចនាសម្ព័ន្ធ ភ័ស្តុភារ និងបុគ្គលិក | ១១០ |
| 2 | កម្មវិធីសិក្សា បទដ្ឋានអប់រំ និងការប្រឡង | ៦៥ |
| 3 | គោលនយោបាយអប់រំ ការរៀបចំផែនការ និងការគ្រប់គ្រងទូទៅ | ១៣៤ |
| 4 | អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ និងនីតិកម្ម | ១០ |
| 5 | ការអប់រំកុមារតូច | ៣៤ |
| 6 | ការផ្តល់ការអប់រំនៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ | ៦១ |
| 7 | សាលារៀនឯកជន និងស្ថាប័នអប់រំដទៃទៀត | ១១ |
| 8 | ការអប់រំក្រៅប្រព័ន្ធ និងបំណិនជីវិត | ៤២ |
| 9 | ការអប់រំកម្រិតឧត្តមសិក្សា និង ការស្រាវជ្រាវវិទ្យាសាស្ត្រ | ៣២ |
| 10 | ការអប់រំគរុកោសល្យ និងការបណ្តុះបណ្តាលវិក្រឹតការ | ២៩ |
| 11 | មុខងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ៖ យុវជន និងកីឡា | ៤៤ |
| **សរ** | | **៥៧៣** |

# សំណើបែងចែកមុខងារក្នុងវិស័យអប់រំ

| មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|
| ការគ្រប់គ្រង | គ្រប់គ្រងការអប់រំថ្នាក់ឧត្តមសិក្សា | គ្រប់គ្រងការអប់រំថ្នាក់មធ្យមសិក្សា (វិទ្យាល័យ និងអនុវិទ្យាល័យ) | • គ្រប់គ្រងការអប់រំថ្នាក់បឋម សិក្សា<br>• គ្រប់គ្រងការអប់រំកុមារតូច និងអប់រំក្រៅប្រព័ន្ធ |

# ការបែងចែកតួនាទីសម្រាប់គ្រប់គ្រងមុខងារគ្រប់គ្រងបឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ

| ល.រ | មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ១ | **គោលនយោបាយ និងផែនការអប់រំជាតិ** | រៀបចំគោលនយោបាយ និងផែនការអប់រំជាតិសម្រាប់ថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | | |
| ២ | **កម្មវិធីសិក្សា និងបទដ្ឋាន** | រៀបចំកម្មវិធីសិក្សា និងបទដ្ឋានសម្រាប់ថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | | |

# ការបែងចែកមុខងារសម្រាប់គ្រប់គ្រងបឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ (ត)

| ល.រ | មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៣ | **ហេដ្ឋារចនាសម្ព័ន្ធ ភស្តុភារ** | • កំណត់ស្តង់ដារសម្រាប់ការបង្កើតសាលាថ្មី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ<br>• ពិនិត្យ និងអនុម័តលើសំណើសុំបង្កើតសាលាបឋមសិក្សា | ជួយគាំទ្រ និងត្រួតពិនិត្យលើការអនុវត្តតាមស្តង់ដារដែលបានកំណត់ | - លើកសំណើបង្កើតសាលាបឋមសិក្សា និងមត្តេយ្យសិក្សា<br>- លើកសំណើ និងអនុវត្តកិច្ចលទ្ធកម្ម និងការសាងសង់ ជួសជុល និងថែទាំអគារសាលារៀន<br>- ចាត់ចែង និងគ្រប់គ្រងសំភារៈ បរិក្ខា និងចំណាយប្រតិបត្តិរដ្ឋបាល<br>- រៀបចំបែបបទ និងបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ |

# ការបែងចែកមុខងារសម្រាប់គ្រប់គ្រងបឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ (ត)

| ល.រ | មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៤ | **ការទទួលស្គាល់គុណភាពអប់រំ** | វាយតម្លៃការអប់រំថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | គាំទ្រការវាយតម្លៃការអប់រំថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | |
| ៥ | **គ្រូ និងបុគ្គលិកអប់រំ** | • ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបឋមសិក្សា<br>• ផ្ទេរគ្រូ និងបុគ្គលិកអប់រំពីខេត្តមួយទៅខេត្តមួយ | • គាំទ្រការរៀបចំប្រឡងជ្រើសរើសគ្រូ<br>• គាំទ្រការបណ្តុះបណ្តាលគ្រូ និងអភិវឌ្ឍវិជ្ជាជីវៈគ្រូ<br>• ផ្ទេរគ្រូពីក្រុង ស្រុកមួយទៅក្រុង ស្រុកមួយក្នុងដែនសមត្ថកិច្ចខេត្តសាមី | – រៀបចំផែនការជ្រើសរើសគ្រូ និងបុគ្គលិកអប់រំកម្រិតបឋមសិក្សា និងអប់រំកុមារតូច<br>– ជ្រើសរើសគ្រូអប់រំក្រៅប្រព័ន្ធ<br>– គ្រប់គ្រងគ្រូ និងបុគ្គលិកអប់រំដែលបានផ្ទេរទៅឲ្យក្រុង ស្រុ<br>– ការផ្ទេរគ្រូ ឬបុគ្គលិកអប់រំនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុកសាមី |

## ការបែងចែកមុខងារសម្រាប់គ្រប់គ្រងបឋមសិក្សា កុមារតូច និង អប់រំក្រៅប្រព័ន្ធ (ត)

| ល.រ | មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៦ | លិខិតអនុញ្ញាតផ្តល់សេវាអប់រំ | • កំណត់ស្តង់ដារ (លក្ខខណ្ឌ នីតិវិធី បែបបទ កម្រៃ រយៈពេល) | | ចេញលិខិតអនុញ្ញាតបើក:<br>• ថ្នាក់បឋមសិក្សាឯកជន (កម្មវិធីជាតិ)<br>• ថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីជាតិ និងអន្តរជាតិ)<br>• ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ<br>• ក្លឹបហាត់ប្រាណ<br>• អាជីវកម្មលក់សម្ភារកីឡា |

## ផែនការសម្រាប់ការផ្ទេរ

Conditional Grant

- ផ្ទេរតាមដំណាក់កាល៖
  - ឆ្នាំ២០១៥ ៖ រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរ
  - នៅឆ្នាំ២០១៦ អាចផ្ទេរទៅឱ្យស្រុកចំនួនពី១០ទៅ២០ស្រុក
  - នៅឆ្នាំ២០១៧ អាចពង្រីកការផ្ទេរទៅឱ្យស្រុកមួយចំនួនបន្ថែមទៀត ផ្អែកលើបទពិសោធន៍ដែលបានអនុវត្តកន្លងមក

MOEYS

# សូមអរគុណ

# កិច្ចប្រជុំកម្រិតបច្ចេកទេស
# ដើម្បីពិភាក្សាលើកិច្ចដំណើរការផ្ទេរមុខងារ
# ក្នុងវិស័យសុខាភិបាល

## មុខងារស្នូលនៃក្រសួងសុខាភិបាល

| ល.រ | មុខងារស្នូល | #មុខងាររង |
|---|---|---|
| 1 | គោលនយោបាយ បទបញ្ញាត្ត ការគ្រប់គ្រងទូទៅ អភិបាលកិច្ច | ៥១ |
| 2 | ការគ្រប់គង និងការអភិវឌ្ឍធនធានមនុស្ស | ១១ |
| 3 | ការផ្តល់សេវាសុខាភិបាល | ២៤ |
| 4 | ការផ្តល់ហិរញ្ញប្បទានសម្រាប់សេវាសុខភាព | ១០ |
| 5 | ការស្រាវជ្រាវផ្នែកសុខភាព | ០៣ |
| | សរុប | ៩៩ |

# សំណើបែងចែកមុខងារក្នុងវិស័យសុខាភិបាល

| មុខងារ | ក្រសួងសុខាភិបាល | មន្ទីរសុខាភិបាលខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|
| **ការគ្រប់គ្រង** | ការគ្រប់គ្រងទូទៅលើវិស័យសុខាភិបាល | ការគ្រប់គ្រងមន្ទីរពេទ្យបង្អែករាជធានីខេត្ត | ការគ្រប់គ្រងស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក និងមណ្ឌលសុខភាព |

| ល.រ | មុខងារ | ក្រសួងសុខាភិបាល | មន្ទីរសុខាភិបាលខេត្ត | រដ្ឋបាលស្រុក |
|---|---|---|---|---|
| ១ | **គោលនយោបាយ និងផែនការជាតិ** | រៀបចំគោលនយោបាយ និងផែនការជាតិ | | |
| ២ | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | -កំណត់បទដ្ឋាន និងត្រួតពិនិត្យលើការជ្រើសរើស បណ្តុះបណ្តាលពេទ្យ និងការអភិវឌ្ឍវិជ្ជាជីវៈពេទ្យ<br>-រៀបចំការប្រឡងជ្រើសរើសពេទ្យ និងបុគ្គលិក<br>-ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលបន្ត<br>-ការពង្រាយពេទ្យ បុគ្គលិក<br>-ផ្ទេរពេទ្យ និងបុគ្គលិកពីខេត្តមួយទៅខេត្តមួយ??? | -បណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈពេទ្យ (ការបណ្តុះបណ្តាលបន្ត)<br>-ផ្ទេរពេទ្យពីក្រុង ស្រុកមួយទៅក្រុង ស្រុកមួយនៅក្នុងដែនសមត្ថកិច្ចនៃខេត្តសាមី | -រៀបចំផែនការជ្រើសរើសពេទ្យ និងបុគ្គលិក<br>-គ្រប់គ្រងពេទ្យ និងបុគ្គលិក<br>-ការផ្ទេរពេទ្យ ឬបុគ្គលិកនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក |

## ការបែងចែកតួនាទីសម្រាប់មុខងារគ្រប់គ្រងមន្ទីរពេទ្យបង្អែកក្រុង ស្រុក និងមណ្ឌលសុខភាព (ត)

| ល.រ | មុខងារ | ក្រសួងសុខាភិបាល | មន្ទីរសុខាភិបាលខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៣ | **ការផ្តល់សេវាសុខភាព** | - កំណត់និយាម/ស្តង់ដារសម្រាប់ការបង្កើតមន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព, ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់សម្ភារ បរិក្ខារ<br>- កំណត់ស្តង់ដារអប្បបរមាសម្រាប់ការផ្តល់សេវាសុខភាព | ជួយគាំទ្រ និងត្រួតពិនិត្យលើការអនុវត្តតាមនិយាមដែលបានកំណត់ | - លើកសំណើបង្កើតមន្ទីរពេទ្យបង្អែកស្រុក, មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- លើកសំណើ និងអនុវត្តកិច្ចលទ្ធកម្ម និងការសាងសង់ ជួសជុល និងថែទាំអគារ ហេដ្ឋារចនាសម្ព័ន្ធ??<br>- ចាត់ចែង និងគ្រប់គ្រងសំភារៈ បរិក្ខា និងចំណាយប្រតិបត្តិការរដ្ឋបាល<br>- បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ<br>- គ្រប់គ្រងការផ្តល់សេវាសុខភាពរបស់មន្ទីរពេទ្យបង្អែក, មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព |

## ការបែងចែកតួនាទីសម្រាប់មុខងារគ្រប់គ្រងមន្ទីរពេទ្យបង្អែកក្រុង ស្រុក និងមណ្ឌលសុខភាព (ត)

| ល.រ | មុខងារ | ក្រសួងសុខាភិបាល | មន្ទីរសុខាភិបាលខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៤ | **ផ្តល់ហិរញ្ញប្បទានសម្រាប់សេវាសុខភាព** | • រៀបចំគោលនយោបាយបទដ្ឋាននានា<br>• ការកៀរគរធនធាន<br>• ការវិភាជន៍ធនធាន | • ការកៀរគរធនធាន | • ការកៀរគរធនធាន<br>• គ្រប់គ្រង និងចាត់ចែងហិរញ្ញប្បទានផ្តល់សេវាសុខភាពនៃមន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព |
| ៥ | **ការស្រាវជ្រាវផ្នែកសុខភាព** | - តាមករណីនីមួយៗ | - ??? | - ??? |

## ការបែងចែកតួនាទីសម្រាប់មុខងារគ្រប់គ្រងមន្ទីរពេទ្យបង្អែកក្រុង ស្រុក និងមណ្ឌលសុខភាព (ត)

| ល.រ | មុខងារ | ក្រសួងសុខាភិបាល | មន្ទីរសុខាភិបាលខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| ៦ | **ការអនុញ្ញាតលើការផ្តល់ សេវាសុខភាព** | ??? | ??? | - បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុន និងក្រោយសម្រាល<br>- បន្ទប់ថែទាំជម្ងឺ<br>- បន្ទប់ព្យាបាលដោយចលនា<br>- ឱសថស្ថានរង ក<br>- ឱសថស្ថានរង ខ<br>- បន្ទប់ពិគ្រោះព្យាបាលជម្ងឺទូទៅ<br>- បន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់ធ្មេញ<br>- ចេញវិញ្ញាបនបត្របញ្ជាក់សុខភាព<br>- ចេញវិញ្ញាបនបត្របញ្ជាក់កម្រិតអនាម័យតាមភោជនីយដ្ឋាន (តាមកម្រិតនៃមុខងារដែលបានធ្វើប្រតិភូកម្មរបស់ក្រសួងទេសចរណ៍) |

## ផែនការសម្រាប់ការផ្ទេរ

- ផ្ទេរតាមដំណាក់កាល៖
  - ឆ្នាំ២០១៥ ៖ រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរ
  - នៅឆ្នាំ២០១៦៖
    - ជម្រើសទី១៖ ស្នើផ្ទេរស្រុកប្រតិបត្តិដែលមានវិសាលភាពតែ១ស្រុក (មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព) ចំនួន១០ទៅ១៥ លើចំនួនសរុប៣២ ស្រុកប្រតិបត្តិ ទៅរដ្ឋបាលក្រុង ស្រុក
    - ជម្រើសទី២៖ ស្នើផ្ទេរស្រុកប្រតិបត្តិ ដែលមានវិសាលភាពគ្របដណ្តប់លើខេត្តទាំងមូល (ចំនួនសរុប៧) ទៅរដ្ឋបាលខេត្ត
  - នៅឆ្នាំ២០១៧ អាចពង្រីកការផ្ទេរនេះទៅឱ្យស្រុកពាក់ព័ន្ធមួយចំនួនបន្ថែមទៀត ផ្អែកលើបទពិសោធន៍

- MoH [illegible]

# អរគុណ

ជំពូក 21 :

# កិច្ចប្រជុំកម្រិតបច្ចេកទេស
# ដើម្បីពិភាក្សាលើកិច្ចដំណើរការផ្ទេរមុខងារ
# ក្នុងអភិវឌ្ឍន៍ជនបទ

## មុខងារស្នូលនៃក្រសួងអភិវឌ្ឍន៍ជនបទ

| ល.រ | មុខងារស្នូល | # មុខងាររង |
|---|---|---|
| 1 | ការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក | ០១ |
| 2 | ការអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ និងបទបញ្ញត្តិ | ០១ |
| 3 | ការអភិវឌ្ឍសហគមន៍ជនបទ | ០៥ |
| 4 | ការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ០៣ |
| 5 | ការថែទាំសុខភាព និងអនាម័យជនបទ | ០៤ |
| 6 | ការផ្គត់ផ្គង់ទឹកជនបទ | ០៩ |
| 7 | ការអភិវឌ្ឍផ្លូវជនបទ | ០៥ |
| 8 | ការអភិវឌ្ឍសហគមន៍ជនជាតិភាគតិច | ០៨ |
| 9 | កសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស | ០៤ |
| | | ៤០ |

# ស្ថិតិ និងប្រភេទផ្លូវជនបទ

ប្រភេទផ្លូវជនបទ៖

- ប្រភេទទី ១ ពីស្រុក ទៅស្រុក - ៧.១៣៨គ.ម (១៩,៣%)
- ប្រភេទទី ២ ពីស្រុក ទៅឃុំ- ៦.៦៧៤គ.ម (១៨%)
- ប្រភេទទី ៣ ពីឃុំ ទៅឃុំ-៩.១២៣គ.ម (២៤,៦%)
- ប្រភេទទី ៤ ពីឃុំ ទៅភូមិ និងពីភូមិ ទៅភូមិ- (៣៨,១%)

# សំណើរបស់លេខាធិការដ្ឋាន

| ប្រភេទផ្លូវ | ក្រសួងអភិវឌ្ឍន៍ជនបទ | មន្ទីរអភិ/ខេត្ត | រដ្ឋបាលក្រុង ស្រុក | រដ្ឋបាលឃុំ សង្កាត់ |
|---|---|---|---|---|
| ប្រភេទទី ២ ពី ស្រុក ទៅឃុំ | •គោលនយោបាយ<br>•ផែនការជាតិ<br>•កំណត់ស្តង់ដារ<br>•តាមដានត្រួតពិនិត្យ | | •សាងសង់<br>•ជួសជុលខួប<br>•ជួសជុលប្រចាំ | |
| ប្រភេទទី ៣ ពី ឃុំ ទៅឃុំ | | | •សាងសង់<br>•ជួសជុលខួប<br>•ជួសជុលប្រចាំ | |
| ប្រភេទទី ៤ ពី ឃុំ ទៅភូមិ និងពី ភូមិ ទៅភូមិ | | | | •សាងសង់<br>•ជួសជុលខួប<br>•ជួសជុលប្រចាំ |

# យោបល់ត្រឡប់របស់ក្រសួង

- **ស្នើផ្ទេរមុខងារដែលបានកំណត់ក្នុងរបាយការណ៍ រួមមាន៖**
  1. ការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ
  2. អនាម័យជនបទ
  3. ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
  4. ដាក់ផ្លាកសញ្ញាចរាចរណ៍លើផ្លូវជនបទ
  5. ជួសជុលផ្លូវជនបទមានលក្ខណៈជាប្រចាំ

[illegible]



[illegible]

[illegible] → DPM [illegible]

[illegible]